# មេរៀនទី១៖ ទំនាយពួកហោរាពីការយាងមករបស់ព្រះយេស៊ូវ

[យេរេមា ៣៣៖១៤-១៦](#)/[អេសាយ ៩៖៦-៧](#)

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/S5ncNOViErE

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/gK4Wbvl1b28

**គោលបំណង៖**ព្រះបានសន្យាថានឹងបញ្ជូនព្រះអង្គសង្គ្រោះមក

**ខគម្ពីរចងចាំ៖ ម៉ាថាយ១៖២៣** *«មើលនាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ហើយព្រះនាមបុត្រនោះត្រូវហៅ ថា អេម៉ាញូអែល» ដែលប្រែថា ព្រះអង្គទ្រង់គង់ជាមួយនឹងយើងខ្ញុំ។*

**ចំរៀង** ( *យូធូបលីង* )៖

១. អបអរសាទរ https://youtu.be/K72xD0x_cyg

២. ហេតុអ្វី? https://youtu.be/okP4f2cWE0w

៣. ចូរទៅប្រាប់គេនៅឯភ្នំ https://youtu.be/z9qbWLyIWvA

## ១. អធិស្ឋាន

កូនសូមអរគុណព្រះអង្គសំរាប់ថ្ងៃនេះ ដែលកូននៅតែមានជីវិតរស់នៅនិងបន្តរៀនពីទ្រង់រហូត សូមព្រះវិញ្ញាណបរិសុទ្ធជួយកូនឲ្យយល់ពីព្រះបន្ទូលសន្យានៅថ្ងៃនេះផង។ កូនអធិស្ថានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត

សំភារៈដែលត្រូវការ៖ សរសេរពាក្យ "គម្ពីរសញ្ញាចាស់" "គម្ពីរសញ្ញាថ្មី" "៣៩កំណ្ឌ" "២៧កំណ្ឌ" "៦៦កំណ្ឌ" នៅលើក្រដាសផ្សេងៗគ្នា ហើយបិទវានៅលើជញ្ជាំងតាមជ្រុងនីមួយនៅក្នុងបន្ទប់។

ក.ឲ្យកុមារទាំងអស់ឈរនៅចំកណ្តាលថ្នាក់រៀន។ ត្រូវប្រាប់ឲ្យពួកគេរត់ទៅកាន់ទីតាំងដែលមានក្រដាសជាចំលើយត្រឹមត្រូវ។

ខ. តើនៅក្នុងគម្ពីរសញ្ញាចាស់មានប៉ុន្មានកំណ្ឌ? ( *កុមាររត់ទៅរកចំលើយ "៣៩"* )

គ. តើនៅក្នុងគម្ពីរសញ្ញាថ្មីមានប៉ុន្មានកំណ្ឌ? ( *កុមាររត់ទៅរកចំលើយ "២៧"* )

ឃ. តើគម្ពីរយេរេមានៅក្នុងសញ្ញាចាស់ ឬសញ្ញាថ្មី? ( *កុមាររត់ទៅរកចំលើយ "សញ្ញាចាស់"* )

ង. តើគម្ពីរលូកានៅក្នុងសញ្ញាចាស់ ឬសញ្ញាថ្មី? ( *កុមាររត់ទៅរកចំលើយ "សញ្ញាថ្មី"* )

ច. តើនៅក្នុងព្រះគម្ពីរទាំងមូលមានប៉ុន្មានកំណ្ឌ? ( *កុមាររត់ទៅរកចំលើយ "៦៦"* )

ឆ. ថ្ងៃនេះយើងនិងអានខគម្ពីរ យេរេមា ៣៣៖១៤-១៦។ តើខគម្ពីរនេះនៅក្នុងគម្ពីរសញ្ញាចាស់ ឬគម្ពីរសញ្ញាថ្មី? ( *កុមាររត់ទៅគម្ពីរសញ្ញាចាស់* )

១.សូមពន្យល់កុមារថាខគម្ពីរថ្ងៃនេះគឺជាការសន្យារបស់ព្រះ។ តើអ្វីដែលព្រះបានសន្យានៅក្នុងខគម្ពីរទាំងអស់នេះ? ( *ព្រះបានសន្យាថាទ្រង់នឹងបញ្ជូនព្រះអង្គសង្គ្រោះមក* )

## ៤. ការណែនាំមេរៀន

ព្រះគម្ពីរសញ្ញាចាស់គឺជាផ្នែកមួយនៃព្រះគម្ពីរ ដែលបានសរសេរឡើងមុនពេលដែលព្រះយេស៊ូវប្រសូត្រ។ កំណ្ឌគម្ពីរជាច្រើននៅក្នុងគម្ពីរសញ្ញាចាស់ប្រាប់យើងអំពី ការសន្យារបស់ព្រះដែលទ្រង់នឹងបញ្ជូនព្រះអង្គសង្គ្រោះមក។ ព្រះគម្ពីរសញ្ញាចាស់ប្រាប់យើងថា តើព្រះយេស៊ូវនឹងត្រូវបានគេហៅយ៉ាងដូចម្តេច , ទ្រង់ប្រសូតនៅកន្លែងណា ហើយក៏ប្រាប់យើងពីអ្វីដែលទ្រង់នឹងត្រូវធ្វើផងដែរ។ គ្រប់ទាំងសេចក្តីសន្យាអំពីព្រះយេស៊ូវត្រូវបាន សរសេរនៅក្នុងគម្ពីរសញ្ញាចាស់។ ព្រះចង់ឲ្យយើងរង់ចាំព្រះអង្គសង្គ្រោះ ហើយទ្រង់ចង់បង្ហាញឲ្យមនុស្ស បានដឹងថាព្រះយេស៊ូវពិតជាព្រះអង្គសង្គ្រោះមែន។ តើមាននរណាម្នាក់ធ្លាប់បានសន្យាជាមួយអ្នក ហើយអ្នកត្រូវរង់ចាំអោយការសន្យានេះក្លាយជាការពិតដែរឬទេ ?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះគម្ពីសញ្ញាចាស់គឺមានសារៈសំខាន់ណាស់ ពីព្រោះបាននិយាយពីការសន្យាថានឹងមាន ព្រះសង្គ្រោះយាងមកសំរាប់យើងរាល់គ្នា។ តាមពិតទៅព្រះគម្ពីសញ្ញាចាស់បានពិពណ៌នាពីការយាងមករបស់ព្រះអង្គសង្គ្រោះនោះមានលក្ខណៈបែបណា។ នៅក្នុង ព្រះគម្ពីរ **អេសាយ ៩៖៦** បានចែងថា "ហើយគេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ជួយគំនិត យ៉ាងអស្ចារ្យ ព្រះដ៏មានព្រះចេស្តា ព្រះវរបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព" ។ ព្រះអង្គសង្គ្រោះដែលត្រូវយាងមក បានសន្យានឹងយើងនៅក្នុងគម្ពីរសញ្ញាចាស់ ថាគឺជាព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ។ អ្នកជួយគំនិត នឹងជួយយើងពេលយើង យល់ច្រឡំអំពីអ្វីដែលត្រូវធ្វើ។ ព្រះយេស៊ូវព្រះអង្គសង្គ្រោះរបស់យើង គឺជាទីប្រឹក្សាដ៏អស្ចារ្យរបស់យើង។ ព្រះអង្គសង្គ្រោះគឺជាព្រះដ៏មានព្រះចេស្តា។ ព្រអង្គសង្គ្រោះនឹងមានអំណាចដើម្បីនាំយើងត្រឡប់ទៅកាន់ ព្រះវរបិតាវិញ ដោយទ្រង់សុគតលើឈើឆ្កាងជំនួសយើង។ ព្រះអង្គសង្គ្រោះក៏ជាព្រះ វរបិតាដ៏គង់នៅអស់ កល្បជានិច្ចផងដែរ។ ឪពុកខាងសាច់ឈាមរបស់យើងនឹងមិននៅជាមួយយើងរហូតនោះទេពីព្រោះយើងគឺជាមនុស្ស។ ប៉ុន្តែព្រះសង្គ្រោះរបស់យើងគឺគង់នៅអស់កល្ប ហើយទ្រង់នឹងគង់នៅជាមួយយើងជារៀងរហូត! ព្រះអង្គសង្គ្រោះ ទ្រង់ជាម្ចាស់នៃសេចក្តីសុខសាន្ត។ លោកីយ៍នេះពោរពេញទៅដោយបញ្ហានិងការលំបាកជាច្រើន។ មនុស្សតែងតែមានកំហឹងឬឈ្លោះប្រកែកគ្នា។ មនុស្សមានភាពអាត្មានិយម ហើយនឹងឈ្លោះទាស់ទែង គ្នាដើម្បីដណ្តើមយកអ្វីដែលគេចង់បាន។ ប៉ុន្តែព្រះអង្គសង្គ្រោះទ្រង់ជាម្ចាស់នៃសេចក្តីសុខសាន្ត។ ព្រះយេស៊ូវនឹងប្រទានឲ្យយើងនូវសេចក្តីសុខសាន្តដែលលោកីយ៍មិនអាចឲ្យយើងបាន។ នេះហើយគឺជា ព្រះអង្គសង្គ្រោះដែលព្រះបានសន្យាសំរាប់យើង។ អរគុណព្រះជាម្ចាស់ដែលទ្រង់តែងតែរក្សាការសន្យារបស់ទ្រង់ ហើយបានបញ្ជូនព្រះអង្គសង្គ្រោះមកយើងនៅថ្ងៃបុណ្យណូអែលកាលពី ២000 ឆ្នាំមុន!

## ៦. សំនួរពិភាក្សា

១. តើហេតុអ្វីបានជាកំណ្ឌគម្ពីសញ្ញាចាស់មានសារៈសំខាន់ ?

*( សញ្ញាចាស់បានសន្យាពីព្រះអង្គ សង្គ្រោះសំរាប់យើង )*

២. តើព្រះនាមទាំង៤នៅក្នុងគម្ពីរ អេសាយ ៩៖៦ ដែលផ្តល់ឲ្យព្រះអង្គសង្គ្រោះមានអ្វីខ្លះ ?

*( ជាព្រះដ៏ជួយគំនិត ព្រះដ៏មានព្រះចេស្តា ព្រះវរបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព )*

៣. តើព្រះបានរក្សាការសន្យារបស់ទ្រង់ក្នុងការបញ្ជូនព្រះអង្គសង្គ្រោះមកយើងដោយរបៀបណា ?

*( ទ្រង់បានបញ្ជូនព្រះយេស៊ូវមកយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធដែលបង្កើតឲ្យមានជាថ្ងៃបុណ្យណូអែលនេះឡើង )*

៤. តើពេលនេះប្អូនត្រូវការឈ្មោះមួយណា ក្នុងចំណោមឈ្មោះទាំង៤ របស់ព្រះអង្គសង្គ្រោះ ?
*( ទុកឲ្យកុមារឆ្លើយ )*

**៧. ល្បែងកំសាន្ត** **« តើព្រះសង្គ្រោះមានលក្ខណៈដូចម្ដេច ?»**



សំភារៈដែលត្រូវការៈ សូមបោះពុម្ពខគម្ពីរ **អេសាយ ១១៖១-៥** និងរូបភាពមែកឈើ( សូមមើលនៅទំព័រខាងក្រោម )

១. ចែកកុមារជាក្រុម ដោយក្នុងមួយក្រុមមានគ្នាពី៣-៤នាក់។ សូមធ្វើឲ្យប្រាកដថា នៅក្នុងក្រុមនីមួយៗមានកុមារម្នាក់អាចអានអក្សរខ្មែរបាន។

២.សូមឲ្យកុមារផាត់ពណ៌ ឬគូសបន្ទាត់ពីក្រោមខគម្ពីរដែលនិយាយពី លក្ខណៈរបស់ព្រះអង្គសង្គ្រោះ។ *( ចម្លើយមួយចំនួនអាចជា៖ មានប្រាជ្ញា យល់ដឹង ព្រះវិញ្ញាណនៃការជួយគំនិត មានព្រះចេស្ដា ។ល។ )*

៣.ក្រុមនីមួយៗត្រូវអាននូវចម្លើយដែលពួកគេបានរកឃើញអំពីព្រះអង្គសង្គ្រោះ។ បន្ទាប់មកគ្រូត្រូវតែចែកឱ្យក្រុមនីមួយៗនូវលក្ខណៈមួយរបស់ព្រះអង្គសង្គ្រោះដែលព្រះបានសន្យាដល់យើង ដោយសរសេរពាក្យទាំងអស់នោះនៅលើមែកឈើ ហើយកាត់វានោះចេញ។ ( *កុមារគួរតែផាត់ពណ៌ និងតុបតែង លើមែកឈើនោះ* )

៤. សូមបិតមែកឈើនោះនៅលើជញ្ជាំង ហើយរៀបចំឲ្យចេញជាដើមគ្រីស្មាស់។

**៨. ខគម្ពីរចងចាំ**

**ម៉ាថាយ ១៖២៣** «មើល នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ ហើយព្រះនាមបុត្រនោះត្រូវហៅថា អេម៉ាញូអែល ដែលប្រែថា ព្រះអង្គទ្រង់គង់ជាមួយនឹងយើងខ្ញុំ»។

**៩. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**១០. អធិស្ឋាន**

កូនសូមអរគុណព្រះសំរាប់សេចក្ដីសន្យាជាមួយយើងខ្ញុំ ក្នុងការប្រទានព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យព្រះដ៏មានព្រះចេស្ដា ព្រះវរបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព ។ អធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ ។ អាម៉ែន

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន )**
តាំងពីយូរយារណាស់មកហើយព្រះបាន ជ្រើសរើសដើម្បីរៀបចំចិត្តរបស់រាស្ត្រទ្រង់ជាមួយនឹងដំណឹងថា ព្រះអង្គសង្គ្រោះនឹងយាងមក។ ដូចដែលអ្នករៀបចំសំរាប់គ្រីស្មាស់ សូមចំណាយពេលខ្លះដើម្បីអនុញ្ញាតឲ្យព្រះ បន្ទូលរបស់ព្រះនៃក្ដីសង្ឃឹម និងសេចក្ដីសង្គ្រោះបានជ្រៀតចូលមកក្នុងអ្នក។ សូមជ្រើសរើសជឿលើក្ដីសន្យារបស់ព្រះ ហើយពិចារណាអំពីការអស្ចារ្យរបស់ព្រះយេស៊ូវជាបុត្ររបស់ព្រះដែលកំពុងយាងមក ដើម្បីអ្នកក្នុងនាមជាទារកដែលគ្មានទីពឹងដើម្បីសង្គ្រោះយើង។ សូមចំណាយពេលស្ងប់ស្ងាត់បន្តិចក្នុងថ្ងៃនេះ សូមមានអំណរនៅក្នុងការអស្ចារ្យដ៏អស្ចារ្យនៃកំណើតរបស់ព្រះយេស៊ូវ។

## អេសាយ ១១:១-១៥

មានលំពង់១ នឹងដុះចេញពីគល់របស់អ៊ីសាយហើយមែក១ ដែលចេញពី
ឫសគាត់ នឹងកើតមានផលផ្លែ។ ព្រះវិញ្ញាណនៃព្រះយេហូវ៉ា នឹងសណ្ឋិត
នៅលើអ្នកនោះ គឺជាព្រះវិញ្ញាណនៃប្រាជ្ញានឹងយោបល់ ជាព្រះវិញ្ញាណ
នៃគំនិតវាងវៃ និងឫទ្ធានុភាព ជាព្រះវិញ្ញាណនៃសេចក្ដីចេះដឹង នឹងសេច
ក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា។ អ្នកនោះនឹងរីករាយចំពោះសេចក្ដីកោត
ខ្លាចដល់ព្រះយេហូវ៉ា ហើយនឹងជំនុំជំរះ មិនមែនតាមភ្នែកមើលឃើញ
ឬសំរេចសេចក្ដីតាមត្រចៀកស្តាប់ឮនោះឡើយ។ គឺនឹងជំនុំជំរះពួកទាល់ក្រ
ដោយសេចក្ដីសុចរិត ហើយសំរេចក្តីឲ្យមនុស្សរាបសានៅផែនដីដោយសេច
ក្ដីទៀងត្រង់ ក៏នឹងវាយផែនដីដោយរំពាត់នៃមាត់ខ្លួន ព្រមទាំងប្រហារ
ជីវិតមនុស្សដែលប្រព្រឹត្តអាក្រក់ ដោយខ្យល់ដង្ហើមពីបបូរមាត់ផង។
សេចក្ដីសុចរិតនឹងបានជាខ្សែក្រវាត់ចង្កេះរបស់អ្នកនោះ ហើយសេច
ក្ដីស្មោះត្រង់ជាខ្សែក្រវាត់ចង្កេះរបស់អ្នកនោះ

